# ការបញ្ចេញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី :**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000060009

កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ម៉ោង០៤:៣០នាទី

**ហេតុការណ៍ពាក់ព័ន្ធនឹងដើមទុន ភាគហ៊ុន ឬបំណុល (ទម្រង់ ខ.២)**

| ▼ការសម្រេចបែងចែកភាគលាភ | |
|---|---|
| ១. ទម្រង់នៃការបែងចែកភាគលាភ | ▼ជាសាច់ប្រាក់ |
| ២. ចំនួនភាគលាភសរុប | ចំនួនភាគលាភសរុប: ១៦.១០៧.២៦៧.៩៦៨ រៀល<br>➢ ភាគហ៊ុនប្រភេទ “ខ”: ៥.៣០០.០០០.០០០ រៀល<br>➢ ភាគហ៊ុនប្រភេទ “គ”: ១០.៨០៧.២៦៧.៩៦៨ រៀល |
| ៣. អនុបាតនៃការបែងចែកភាគលាភ | អនុបាតនៃការបែងចែកភាគលាភសរុប: ១៧,១៩%<br>➢ អនុបាតនៃការបែងចែកភាគលាភភាគហ៊ុនប្រភេទ “ខ”: ៥,៦៦%<br>➢ អនុបាតនៃការបែងចែកភាគលាភភាគហ៊ុនប្រភេទ “គ”: ១១,៥៣% |
| ៤. ចំនួនភាគលាភក្នុងមួយភាគហ៊ុន | ភាគលាភក្នុងមួយភាគហ៊ុនប្រភេទ “ខ”: ៨២,៣៩ រៀល<br>ភាគលាភក្នុងមួយភាគហ៊ុនប្រភេទ “គ”: ៥០៤,០០ រៀល |
| ៥. រយៈពេលនៃភាគលាភ | ▼ប្រចាំឆ្នាំ |
| ៦.កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ |
| ៧. កាលបរិច្ឆេទទូទាត់ភាគលាភ | ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ |
| ៨.កាលបរិច្ឆេទនៃសេចក្ដីសម្រេច | ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ |
| ៩.បរិយាយ | ការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ |
| ១០.មូលហេតុ | តាមការសម្រេចក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ |

- ឯកសារភ្ជាប់

ហត្ថលេខានិងឈ្មោះបុគ្គលិកទទួលបន្ទុក
ក្នុងការផ្ដល់ព័ត៌មាន

សម សុភាព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខ......៦៩៧......លស.កសស.គណ.ហវ

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តព្រះសីហនុ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពីការបែងចែកភាគលាភរបស់ កសស ប្រចាំឆ្នាំ២០២១

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ **កសស** ឲ្យបានជ្រាបថា យោងតាមការសម្រេចក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៥ ឆ្នាំ២០២២ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ **កសស** បានសម្រេចបែងចែកភាគលាភប្រចាំឆ្នាំ២០២១ ជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដូចខាងក្រោម៖

១. ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend) : សាច់ប្រាក់
២. ប្រភពនៃភាគលាភ : ប្រាក់ចំណេញប្រចាំឆ្នាំ២០២២
៣. ចំនួនដងនៃការបែងចែកភាគលាភ (Period of Dividend) : ប្រចាំឆ្នាំ២០២១
៤. អនុបាតនៃការបែងចែកភាគលាភសរុប (Dividend Payout Ratio) :១៧,១៩%
- អនុបាតនៃការបែងចែកសម្រាប់ភាគហ៊ុនប្រភេទ "ខ" : ៥,៦៦%
- អនុបាតនៃការបែងចែកសម្រាប់ភាគហ៊ុនប្រភេទ "គ" : ១១,៥៣%

៥. ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend) : ១៦.១០៧.២៦៧.៩៦៨ រៀល
- ភាគលាភសរុបសម្រាប់ភាគហ៊ុនប្រភេទ"ខ" : ៥.៣០០.០០០.០០០ រៀល
- ភាគលាភសរុបសម្រាប់ភាគហ៊ុនប្រភេទ"គ" : ១០.៨០៧.២៦៧.៩៦៨ រៀល

៦. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសរុប (Dividend per Share)
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនប្រភេទ"ខ": ៨២,៣៩ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនប្រភេទ"គ": ៥០៤,០០រៀល

៧. កាលបរិច្ឆេទអិចឌីវីដិនដ៍ (Ex-Dividend) ឬអិចរាយដ៍ (Ex-right) : **ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២**
៨. កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ (Record Date) : **ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២**
៩. កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) : **ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២**

**បញ្ជាក់៖**

- ភាគហ៊ុនិកមានសិទ្ធិទទួលបានភាគលាភដូចបានកំណត់ខាងលើ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការ ដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើង នៅ**ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២**។

- ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅ**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២** នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។
- ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិ នៅ**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២** នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។
- ការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ នឹងចាប់ផ្តើមពី**ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២** ដល់ **ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២** នៅរៀងរាល់ថ្ងៃធ្វើការ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ **កសស** ដូចខាងក្រោម៖

➢ **ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន: ជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះនរោត្តម សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

១. **លោក លឹម អាន**: ប្រធានផ្នែកប្រតិបត្តិការ RTP

- ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣ / ៧៧ ៥៦៧ ៩៣៥
- អ៊ីម៉ែល: lim.an@acledabank.com.kh/ lim.phengan@gmail.com

២. **លោក ហួត សុភី** : អនុប្រធានផ្នែកប្រតិបត្តិការ RTP

- ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
- អ៊ីម៉ែល: huot.sophy@acledabank.com.kh

៣. **កញ្ញា សំរិទ្ធ វណ្ណីបុប្ផារង្ស** : បុគ្គលិកផ្នែកប្រតិបត្តិការ RTP

- ទូរស័ព្ទ: (៨៥៥) ៨១ ៦៨៦ ៩៨៨/ ៦១ ២៨៧ ៧៦៦
- អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនមេត្តាទទួលជ្រាបជាព័ត៌មាន ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គីមឈន់**

**ចម្លងជូន៖**

- និយ័តករមូលបត្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ផ្សារមូលបត្រកម្ពុជា
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
  (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)
  "ដើម្បីជូនផ្សព្វផ្សាយ"

ឯកសារ-កាលប្បវត្តិ